Khmer | ខ្មែរ

# ករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (DUTY OF CANDOUR)

## អ្វីខ្លះដែលនឹងត្រូវរំពឹង



អ្នកជំងឺ និងក្រុមគ្រួសារ ឬអ្នកថែទាំរបស់ពួកគេមានសិទ្ធិទទួលបានការពន្យល់ពេញលេញ និងការសុំទោសនៅពេលដែលអ្នកជំងឺម្នាក់ទទួលរងនូវការឈឺចាប់ពីគ្រោះថ្នាក់ខ្លាំង ដែលត្រូវបានគេស្គាល់ថាជា ព្រឹត្តិការណ៍សុវត្ថិភាពអ្នកជំងឺរងផលប៉ះពាល់ធ្ងន់ធ្ងរ (SAPSE)។ ដំណើរការបើកចំហ និងស្មោះត្រង់នេះហៅថា ករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candour)។

## តើអ្វីជាគ្រោះថ្នាក់ខ្លាំង?

គ្រោះថ្នាក់ខ្លាំងគឺជា**ព្រឹត្តិការណ៍សុវត្ថិភាពអ្នកជំងឺរងផលប៉ះពាល់ធ្ងន់ធ្ងរ (SAPSE)** ហើយជាព្រឹត្តិការណ៍មួយដែល៖

- បានកើតឡើងខណៈពេលដែលអ្នកជំងឺកំពុងទទួលការថែទាំពីសេវាកម្មសុខភាព និង
- បាននាំមកនូវលទ្ធផលដោយអចេតនា ឬមិនបានរំពឹងទុក
  - គ្រោះថ្នាក់ដល់រាងកាយមធ្យម ឬធ្ងន់ធ្ងរ
  - គ្រោះថ្នាក់ដល់ផ្នែកចិត្តសាស្ត្ររយៈពេលយូរ
  - ការស្លាប់។

អ្នកអនុវត្តសុខភាពដែលបានចុះបញ្ជីនឹងពិនិត្យឡើងវិញលើព្រឹត្តិការណ៍នោះដើម្បីកំណត់ថាគ្រោះថ្នាក់ខ្លាំងនោះបានកើតឡើងឬអត់។

**អ្វីខ្លះដែលនឹងត្រូវរំពឹង៖ មានបីដំណាក់កាលសម្រាប់ដំណើរការករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candour)។**

## ដំណាក់កាលទី 1៖ សុំទោស និងផ្តល់ព័ត៌មានដំបូង

### សេវាកម្មសុខភាពនឹងសុំទោស ហើយចែករំលែកព័ត៌មានដំបូងដែលបានដឹងអំពីគ្រោះថ្នាក់ដែលបានជួបប្រទះ៖

នៅក្នុងររយៈពេល **24 ម៉ោង** នៃគ្រោះថ្នាក់ដែលកំពុងត្រូវបានទទួលស្គាល់ដោយសេវាកម្មសុខភាព។ សេវាកម្មសុខភាពនឹងផ្តល់នូវការសុំទោសពិតប្រាកដមួយដល់អ្នកជំងឺ និង/ឬក្រុមគ្រួសារ ឬអ្នកថែទាំ ហើយចែករំលែកព័ត៌មានណាមួយដែលបានដឹងនៅពេលនោះ។

### សេវាកម្មសុខភាពនឹងចាត់វិធានការដើម្បីរៀបចំការប្រជុំមួយអំពីករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candour)៖

នៅក្នុងរយៈពេល **3 ថ្ងៃធ្វើការ** នៃគ្រោះថ្នាក់ដែលកំពុងត្រូវបានទទួលស្គាល់ដោយសេវាកម្មសុខភាព ដូចជាការពិភាក្សាអំពីពេលវេលា និងទីកន្លែងដែលកិច្ចប្រជុំនឹងត្រូវធ្វើឡើង។

### សិទ្ធិរបស់អ្នក

- អ្នកនឹងមានមនុស្សទំនាក់ទំនងចម្បង ឬមន្ត្រីទំនាក់ទំនងអ្នកប្រើប្រាស់ម្នាក់ ដើម្បីដើរតួនាទីជាអ្នកទំនាក់ទំនងសំខាន់របស់អ្នកក្នុងអំឡុងពេលដំណើរការនេះ
- អ្នកអាចសម្រេចចិត្តមិនចូលរួមក្នុងដំណើរការករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candour) នេះ ដែលត្រូវបានគេហៅថាការជ្រើសយកមិនចូលរួម ប៉ុន្តែត្រូវតែធ្វើឡើងតាមរយៈសេចក្តីថ្លែងការណ៍មួយដែលបានចុះហត្ថលេខា ដែលសេវាកម្មសុខភាពអាចផ្តល់ឱ្យ
- អ្នកអាចស្នើសុំការពន្យារពេលក្នុងដំណើរការនេះ ប្រសិនបើអ្នកមិនទាន់ត្រៀមខ្លួនរួចរាល់ទេ
- អ្នកអាចជ្រើសរើសឱ្យមានអ្នកថែទាំ ឬសមាជិកគ្រួសារម្នាក់នៅជាមួយអ្នកពេញមួយដំណើរការនេះ
- អ្នកអាចស្នើសុំការគាំទ្រពីសេវាកម្មសុខភាព ឧ. អ្នកបកប្រែភាសាផ្ទាល់មាត់ ទីប្រឹក្សា
- អ្នកអាចស្នើសុំថាមនុស្សជាក់លាក់មួយចំនួនមិនត្រូវមានវត្តមាននៅក្នុងកិច្ចប្រជុំនោះទេ
- អ្នកអាចសម្រេចចិត្តពីរបៀបដែលអ្នកចង់ចូលរួមក្នុងកិច្ចប្រជុំនោះ - តាមរយៈទូរសព្ទ ការហៅទូរសព្ទតាមវីដេអូ នៅមន្ទីរពេទ្យ ឬនៅទីកន្លែងផ្សេងជំនួសវិញ ប្រសិនបើសេវាកម្មមានសមត្ថភាពនឹងធ្វើដូចនោះបាន។

### របៀបដែលអ្នកអាចត្រៀមខ្លួនសម្រាប់កិច្ចប្រជុំ

ដើម្បីជួយអ្នកឱ្យត្រៀមខ្លួនសម្រាប់កិច្ចប្រជុំ អ្នកប្រហែលជាចង់សរសេរទុកអំពី៖

- អ្វីខ្លះដែលអ្នកចងចាំអំពីព្រឹត្តិការណ៍ ឬប្រសិនបើព្រឹត្តិការណ៍នោះបានប៉ះពាល់ដល់អ្នកណាម្នាក់ផ្សេងទៀត អ្វីខ្លះដែលពួកគេប្រហែលជាបានប្រាប់អ្នក
- រាល់សំណួរ ឬមតិណាដែលអ្នកមានអំពី៖
  - អ្វីខ្លះដែលបានកើតឡើង
  - អ្វីខ្លះដែលបានដំណើរការខុស
  - ផលប៉ះពាល់រយៈពេលវែងដែលមានអាចកើតមាន ដែលព្រឹត្តិការណ៍នោះអាចមានចំពោះអ្នក/សមាជិកគ្រួសាររបស់អ្នកនៅពេលខាងមុខ
  - របៀបដែលអ្នកចង់ចូលរួមនៅក្នុងដំណើរការពិនិត្យសើរើឡើងវិញ
- អ្វីផ្សេងទៀតដែលអ្នកចង់ឱ្យអ្នកពិនិត្យសើរើឡើងវិញដឹង។

## ដំណាក់កាលទី 2៖
## រៀបចំកិច្ចប្រជុំអំពីករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (DUTY OF CANDOUR)

### នៅក្នុងកិច្ចប្រជុំអំពីករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (DUTY OF CANDOUR) សេវាកម្មសុខភាពនឹង៖

- ចាត់វិធានការនានាដើម្បីធ្វើឱ្យប្រាកដថាអ្នកមានអារម្មណ៍ត្រូវបានគេគាំទ្រ
- ពន្យល់អំពីអ្វីដែលបានកើតឡើង ដោយផ្អែកលើអ្វីដែលដឹងនៅពេលកិច្ចប្រជុំ
- សុំទោសចំពោះគ្រោះថ្នាក់ដែលធ្វើឱ្យមានការឈឺចាប់
- ផ្តល់ឱកាសឱ្យអ្នកសួរសំណួរនានា និងពន្យល់អំពីអ្វីដែលអ្នកបានជួបប្រទះ
- ពន្យល់អំពីជំហានអ្វីខ្លះដែលពួកគេនឹងធ្វើដើម្បីពិនិត្យសើរើឡើងវិញ ហើយគ្រប់គ្រងព្រឹត្តិការណ៍នោះ និងធ្វើការកែលម្អ
- ពន្យល់ពីការថែទាំតាមដានដែលត្រូវការសម្រាប់អ្នក និងផលប៉ះពាល់ណាមួយ ប្រសិនបើមាន

កិច្ចប្រជុំនេះធ្វើឡើងនៅក្នុងរយៈពេល **10 ថ្ងៃធ្វើការ** នៃគ្រោះថ្នាក់ដែលកំពុងត្រូវបានទទួលស្គាល់ដោយសេវាកម្មសុខភាព។

### សេវាកម្មសុខភាពនឹងផ្តល់ឱ្យអ្នកនូវកំណត់ត្រាពីកិច្ចប្រជុំ៖

នៅក្នុងរយៈពេល **10 ថ្ងៃធ្វើការនៃកិច្ចប្រជុំ** សេវាកម្មសុខភាពនឹងផ្តល់ឱ្យអ្នកនូវច្បាប់ចម្លងនៃកំណត់ត្រានៃកិច្ចប្រជុំនោះ។

### សិទ្ធិរបស់អ្នក

- អ្នកអាចមានមនុស្សជំនួយរបស់អ្នក (ឧទាហរណ៍ សមាជិកគ្រួសារ ឬអ្នកថែទាំ) នៅជាមួយអ្នកនៅក្នុងកិច្ចប្រជុំនេះ
- កិច្ចប្រជុំគឺជាដំណើរការពីរយ៉ាង
  - អ្នកអាចសួរសំណួរណាមួយដែលអ្នកត្រូវការ ដើម្បីជួយអ្នកឱ្យយល់ដឹងពីអ្វីដែលបានកើតឡើង
  - អ្នកអាចចែករំលែកបទពិសោធន៍របស់អ្នកអំពីព្រឹត្តិការណ៍នោះ
- ប្រសិនបើអ្នកគិតថាកំណត់ត្រាប្រជុំខុស ឬបាត់អ្វីមួយ សូមនិយាយ ឬសរសេរទៅកាន់មនុស្សទំនាក់ទំនងចម្បង ឬមន្ត្រីទំនាក់ទំនងអ្នកប្រើប្រាស់។

## ដំណាក់កាលទី 3៖
## បំពេញការពិនិត្យឡើងវិញនៃព្រឹត្តិការណ៍នោះ ហើយរៀបចំរបាយការណ៍មួយ

### សេវាកម្មសុខភាពនឹងបញ្ចប់ការពិនិត្យឡើងវិញនៃព្រឹត្តិការណ៍នោះ និងសរសេររបាយការណ៍មួយ។ ច្បាប់ចម្លងនៃរបាយការណ៍នឹងត្រូវបានចែករំលែកជាមួយអ្នក៖

នៅក្នុងរយៈពេល **50-75 ថ្ងៃធ្វើការ** នៃគ្រោះថ្នាក់ដែលកំពុងត្រូវបានទទួលស្គាល់ដោយសេវាកម្មសុខភាព អ្នកនឹងទទួលបានច្បាប់ចម្លងនៃរបាយការណ៍នោះដែលមានលក្ខខណ្ឌតម្រូវជាអប្បបរមានានាដូចខាងក្រោម៖

- ការសុំទោស
- អង្គហេតុនៃព្រឹត្តិការណ៍នោះ - មានន័យថាអ្វីដែលបានកើតឡើង និងមូលហេតុ។ នេះអាចរួមបញ្ចូលតារាងពេលវេលាដែលនាំទៅដល់ព្រឹត្តិការណ៍នោះ
- ការឆ្លើយតបរបស់សេវាកម្មសុខភាពចំពោះព្រឹត្តិការណ៍នោះ - មានន័យថាអ្វីខ្លះដែលសេវាកម្មសុខភាពបានធ្វើនៅចំពេល និងក្រោយព្រឹត្តិការណ៍នោះ
- ជំហាននានាដែលកំពុងត្រូវបានធ្វើឡើង ដើម្បីបង្ការកុំឱ្យព្រឹត្តិការណ៍ស្រដៀងគ្នានេះកើតឡើងម្តងទៀត។

### សិទ្ធិរបស់អ្នក

- ជាលទ្ធផល សេវាកម្មសុខភាពនឹងសរសេររបាយការណ៍មួយអំពីគ្រោះថ្នាក់ដែលបានជួបប្រទះ និងការកែលម្អណាមួយដែលពួកគេនឹងធ្វើ ហើយចែករំលែកវាជាមួយអ្នក។ វាអាចជារបាយការណ៍ខ្លី ឬវែងមួយ
- ប្រសិនបើអ្នកមិនពេញចិត្តនឹងដំណើរការករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candor) ទេ អ្នកអាចធ្វើការតវ៉ា៖
  - ដោយផ្ទាល់ជាមួយសេវាកម្មសុខភាពនោះ (ត្រូវបានណែនាំឱ្យអ្នកសាកល្បងជាមុន)
  - ទៅកាន់ស្នងការទទួលបន្ទុកបណ្តឹងតវ៉ាទាក់ទងនឹងសុខភាព សូមហៅទូរសព្ទលេខ **1300 582 113**
  - ទៅកាន់ស្នងការទទួលបន្ទុកបណ្តឹងតវ៉ាទាក់ទងនឹងសុខភាពផ្លូវចិត្ត សូមហៅទូរសព្ទលេខ **1800 246 054**
  - ទៅកាន់តុលាការអ្នកពិនិត្យសាកសពរដ្ឋវិចថូរៀ (Coroners Court of Victoria) សូមហៅទូរសព្ទលេខ **1300 309 519**។

### ពេញមួយដំណើរការនោះ អ្នកអាចរំពឹងថា៖

- នឹងត្រូវបានគេស្តាប់ឮអំពីអ្នក
- នឹងត្រូវបានគេប្រព្រឹត្តិដោយមានការគោរព
- នឹងទទួលបានការគាំទ្រដែលអ្នកត្រូវការ
- នឹងមានការធ្វើទំនាក់ទំនងដោយបើកចំហ និងស្មោះត្រង់ពីសេវាកម្មសុខភាព
- នឹងមានការឆ្លើយទៅនឹងសំណួរនានារបស់អ្នក។

### សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**ដើម្បីស្វែងយល់បន្ថែមទៀតអំពីលក្ខខណ្ឌតម្រូវខាងផ្លូវច្បាប់នៃករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candour)**

**ចូលទៅកាន់៖**
**www.safercare.vic.gov.au/duty-of-candour-resources-for-patients-families-and-their-carers**

Safer Care Victoria